# រឿងនិទាន បែកចាន បែកចិត្ត ដោយអនុសេនីយ៍ឯក កែវ មេធ

ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ស្ថានការណ៍សឹកនៅបាត់ដំបងមានសភាពពុះកញ្ជ្រោល តែគ្មានអ្នកណាទាយទុកថា ថ្ងៃនេះជាថ្ងៃចុងក្រោយនៃរបបសាធារណរដ្ឋខ្មែរឡើយ ។

ខ្ញុំ **កែវ មេធ** អនុសេនីយ៍ឯកអាកាសយានិក C47 ប្រចាំការនៅមូលដ្ឋានអាកាស២០១ ខេត្តបាត់ដំបង ។ យប់ថ្ងៃ១៦ មេសា ១៩៧៥ ខ្ញុំ ចេញប្រតិបត្តិការដូចសព្វដង គឺហោះ Loup Garou gunship ដើម្បីជួយគាំទ្រទ័ពថ្មើរជើងដែលការពារខ្សែក្រវាត់ក្រុងបាត់ដំបង ។ ព្រឹកឡើងខ្ញុំមានឱកាសទៅបណ្ណាគាររកមើលសៀវភៅខ្លះដែលខ្ញុំចង់អាន ។ ពេលនោះមានទាហានម្នាក់បានតាមរកខ្ញុំ ហើយប្រាប់ថាលោកបញ្ជាការចង់ជួបខ្ញុំ ។ ខ្ញុំប្រញាប់ធ្វើដំណើរទៅមូលដ្ឋាន២០១ ឯវាលបែកចានភ្លាម ។ លោកមេបញ្ជាការថ្មីវរសេនីយ៍ឯក **នាង លី** និងលោកមេបញ្ជាការរង **ណាឌី តាន់** បានដាក់បញ្ជាឱ្យខ្ញុំរៀបចំយន្តហោះដើម្បីរៀបចំយន្តហោះ C47 ចាក់សាំងរួចស្រេច ហើយ សុំឱ្យលោកវរសេនីយ៍ទោ **ទឹក ហាសុី** មេបញ្ជាការបច្ចេកទេសជួយការពារកុំឱ្យអ្នក



*Paster Medh Patrick Keo*



ជន្លៀសអស់លោកនាយទាហានចេញទៅប្រទេសសៀម ។ លោកទាំងពីរនាក់ត្រូវធ្វើដំណើរទៅកំពង់ឆ្នាំងដើម្បីដោះស្រាយបញ្ហានៅទីនោះ ហើយលោកបញ្ជាក់ទៀតថា ខ្ញុំនឹងប្រាប់ពេលណាដែលត្រូវចេញដំណើរ ។ ខ្ញុំបានណាមករំខាន ព្រោះខ្លួនលោកក៏ត្រូវធ្វើដំណើរតាមយន្តហោះនេះដែរ ។ ខ្ញុំបានយកភរិយានិងកូនខ្ញុំ ព្រមទាំងគ្រួសារ មិត្តខ្ញុំម្នាក់ គឺ ជិន ប៊ុនឡុង (8A) ដែលបានសុំឱ្យយកប្រពន្ធ និងកូនមកជាមួយផងដែរ ។

ប្រហែលម៉ោង១២ថ្ងៃត្រង់ យើងបានទទួលវិទ្យុទាក់ទងពីលោក ណាឌីតាន់ ប្រាប់ថាអស់លោកទាំងអស់រៀបចំចេញដំណើរចុះ ហើយលោកបានចេញពីកំពង់ឆ្នាំងមកដល់ស្រុកមោងឫស្សី ។ ភ្លាមនោះអាកាសយានិកទាំងអស់ដែលមានបេសកកម្មជន្លៀសបាននាំគ្នាចេញពីមូលដ្ឋានទៅវាលយន្តហោះដែលនៅមិនឆ្ងាយប៉ុន្មានពីទីនោះ ។

ខ្ញុំនៅចាំបាន ពេលនោះសហការីខ្ញុំ គឺលោកអនុសេនីយ៍ត្រី ដួង លាង (Co Pilot) និងអនុសេនីយ៍ត្រី អ៊ួង ឆើត ជា (Flight Mechanic) ព្រមទាំងអាកាសយានិក T28 ប្រចាំការនៅបាត់ដំបង៤រូបទៀត គឺអនុសេនីយ៍ឯក ជិន ប៊ុនឡុង, អនុសេនីយ៍ទោ សរ លួង, អនុសេនីយ៍ទោ សាវ ហ៊ួត, អនុសេនីយ៍ទោ ស៊ួស ហឿន និងអាកាសយានិក T41 ២រូប គឺវរសេនីយ៍ត្រី ឡុត ប៉ាន់ចុល និងលោកអនុសេនីយ៍ឯក ទា អ៊ាង ។

ពេលទៅដល់វាលយន្តហោះខ្ញុំប្រញាប់ប្រញាល់អញ្ជើញអស់លោកដែលត្រូវចេញដំណើរឱ្យឡើងលើយន្តហោះ រួចខ្ញុំចាប់បញ្ឆេះម៉ាស៊ីន បន្ទាប់ពីកំដៅម៉ាស៊ីនរួចហើយ ខ្ញុំក៏ចាប់ផ្ដើមចេញដំណើរពីចំណតទៅរកផ្លូវហោះហើរ ។ ពេលនោះព្រឹត្តិការណ៍មិនប្រក្រតីមួយបានកើតឡើង ខ្ញុំឃើញលោក ចុល និងលោក អ៊ាង រត់សំដៅមកយន្តហោះខ្ញុំយ៉ាងត្រហេបត្រហប ធ្វើឱ្យខ្ញុំឆ្ងល់ថា មានរឿងអ្វីកើតឡើង ។ ឃើញដូច្នោះខ្ញុំក៏បង្អង់ល្បឿន ហើយឱ្យឆក់លោកទាំងពីរបញ្ចូលមកក្នុងយន្តហោះ ដែលធ្វើឱ្យលោកទាំងពីរមានការពិបាកយ៉ាងខ្លាំង ដោយសារកម្លាំងខ្យល់ពីម៉ាស៊ីនយន្តហោះទំរាំបានឡើងផុតពីដីមកក្នុងយន្តហោះបាន ។ ភ្លាមនោះខ្ញុំក្រឡេកមើលទៅខាងឆ្វេងដៃខ្ញុំយន្តហោះ T28 ៤គ្រឿងចតនៅទីនោះ ស្រាប់តែឃើញកណ្ដាទាំង៤នាក់នោះលោតចេញមកឈរនៅលើស្លាប ហើយលើកដៃក្រវីជា

សញ្ញាសុំជួយសង្គ្រោះ ។ ដូចណោត់គ្នាឧទ្ធម្ភាគចក្ររបស់លោកវរសេនីយ៍ទោ ឈឹម សោភ័ណ បានចេញដំណើរពីមូលដ្ឋានដើម្បីទៅទទួលលោក ណាឌីតាន់ និង លឹម ចាន់តារា ដែលទើបមកពីកំពង់ឆ្នាំងតាមយន្តហោះ T28 មួយគ្រឿងឈប់ចាំនៅឯចុងផ្លូវយន្តហោះខាងកើត ។ លោក សោភ័ណ បានបន្ទាបយន្តហោះលោក ហើយកណ្តុចារទាំង៤រូបនោះក៏រត់ឡើងឧទ្ធម្ភាគចក្រយ៉ាងត្រដាបត្រដួស រួចមកទើបហោះទៅទទួលលោកទាំងពីរដែលចាំនៅចុងផ្លូវយន្តហោះខាងកើតដូចខ្ញុំបានជម្រាបខាងលើ ហើយបន្តដំណើរឆ្ពោះទៅប្រទេសសៀមតែម្តង ។



និយាយពីយន្តហោះខ្ញុំវិញ ក្នុងពេលកំពុងបើកបរឆ្ពោះទៅផ្លូវហោះហើរ ស្រាប់តែខ្ញុំឃើញឡានហ្ស៊ីបដែលមានបំពាក់ដោយកាំភ្លើងយន្តរបស់លោកស័ក្តិពា សាវ៉ាង បើកទៅចុងផ្លូវយន្តហោះខាងលិចក្នុងគោលបំណងអ្វីមួយ ។

ខ្ញុំសូមជម្រាបអ្នកអានឱ្យជ្រាបថា គឺក្នុងរយៈពេលតែ៣០នាទីប៉ុណ្ណោះក្នុងពេលដែលយើងចាកចេញពីវាលបែកចាន ស្ថានការណ៍ស្លាប់រស់បានកើតឡើងនៅមុខយើងភ្លាម១ពោល គឺយន្តហោះ T41 ពីរគ្រឿងបានត្រូវកាត់ខ្សែអាគុយយន្តហោះ T28 បួនគ្រឿងក៏ត្រូវបានកាត់ខ្សែអាគុយដូចគ្នា ។ សួរថាតើហេតុអ្វីបានជាអ្នកបច្ចេកទេសអាកាសចរធ្វើដូច្នេះ ? ចម្លើយមានពីរ គឺ : ១-មានខ្លះពួកគេជាខ្សែបង្កប់របស់ពួកខ្មែរក្រហម ហើយមានបំណងកុំឱ្យយើងចេញ ដើម្បីទុកឱ្យពួកខ្មែរក្រហមវាអាករពួកយើង ។ ២-មានខ្លះហាក់ច្រណែនថា ពួកយើងរត់ចោលគេ ។

ខ្ញុំត្រឡប់មកឡានហ្ស៊ីបដែលបំពាក់ដោយកាំភ្លើងយន្តវិញ ដែលទៅចតចាំនៅចុងផ្លូវយន្តហោះខាងលិចនោះ ខ្ញុំប្រាកដថា ពួកនេះបម្រុងនឹងបាញ់យន្តហោះខ្ញុំទម្លាក់ជាពុំខាន ។ ដោយឃើញស្ថានការណ៍មិនប្រក្រតីដូច្នេះ ខ្ញុំបានដាក់ក្បាលយន្តហោះទៅកើត ហើយចាប់ចេញដំណើរតែម្តង ដោយហោះពីលិចទៅកើតវិញ ដើម្បីបញ្ចៀសពីការចៃដន្យណាមួយ ។ ខ្ញុំបានហោះជុំវិញក្រុងបាត់ដំបង៣ជុំដើម្បីលាក្រុងជាទីស្នេហារបស់ខ្ញុំ លាស្ទឹងសង្កែ ផ្សារលើ ផ្សារក្រោម ដូនទាវ អន្លង់វិល បែកចាន បែកចិត្ត និងដើម្បីឱ្យបានកម្ពស់៥០០០ជើង (Feet) ហើយដាក់ក្បាលតម្រង់ទៅអូតាប៉ាវតែម្តង ។

**<u>Bye Bye Battambang Hello O Tapao</u>**

និយាយពីលោក ណាឌីតាន់ វិញ តើហេតុអ្វីបានជាគាត់ចតយន្តហោះនៅចុងផ្លូវយន្តហោះខាងកើត ហើយបញ្ជាឱ្យឧទ្ធម្ភាគចក្រទៅយកលោកនៅទីនោះទៅវិញ ?។ ហេតុអ្វីបានជាលោកមិនចូលមកចតដូចធម្មតា ?។ លោក តាន់ បានឱ្យដឹងថា នេះជាល្បិចខ្ពស់ដែលគ្មាននរណាស្មានដល់ ។ លោកមើលឃើញថា នៅកំពង់ឆ្នាំងមានការវឹកវរ អាណាធិបតេយ្យ គ្មានស្តាប់មេ ស្តាប់កើយ បើដូច្នេះបាត់ដំបងក៏នឹងមានស្ថានភាពដូចគ្នានេះដែរ ។ បើលោកចូលចតដូចប្រក្រតីនោះ លោកប្រាកដជាគ្មានវាសនាហោះឡើងបានវិញទេ ។ ម្យ៉ាងទៀតលោកបានបញ្ជាតាមវិទ្យុឱ្យកណ្តុចារចេញអស់ ហើយ១សល់តែឧទ្ធម្ភាគចក្រមួយគត់ដែលត្រូវសង្គ្រោះជីវិតលោកជាចុងក្រោយ ។ លោកកំប្លែងថា ទាល់តែមើលកុនចិន១០រឿងទើបបានរកឃើញល្បិចដ៏មហាកំពូល និងដ៏មហាអស្ចារ្យនេះ ។

ជាវាសនាល្អយន្តហោះខ្ញុំត្រូវបានមើលការខុសត្រូវដោយលោក តឹក ហង់រី និងបុគ្គលិក Flight Mechanic អ៊ឹង ឆើត យ៉ាងប្រុងប្រយ័ត្ន បើមិនដូច្នោះទេ វាសនាមនុស្ស២៦នាក់ដែលនៅក្នុងយន្តហោះនេះប្រាកដជាធ្លាក់ទៅក្នុងកណ្តាប់ដៃខ្មែរក្រហមហើយ ។ បន្ទាប់មកទៀតលោកអ្នកប្រាកដជាដឹងថា តើវាទៅជាយ៉ាងណា ? ។

ខ្ញុំបានមកដល់អូតាប៉ាវដោយសុវត្ថិភាព ហើយចាប់ផ្តើមជាជនភៀសសឹកភ្លាម ។ អាជ្ញាធរអាមេរិកាំងសុំដកកាំភ្លើងពីខ្ញុំ រួចមកគេច្រានពួកយើងទាំងអស់គ្នាឱ្យចូលទៅក្នុងជំរំក្រណាត់សំពត់មួយជួរ ធ្វើឱ្យយើងអាណិតខ្លួនចង់យំបន្តិច ចង់សើចបន្តិច ។ ក្រោយមកបន្តិចគេចាប់យើងបញ្ចូលដាក់ក្នុងយន្តហោះដ៏ធំមួយ ហើយនាំយើងមកកាន់ជើងមេឃថ្មី ។ អ្វី១ក៏ថ្មីទាំងអស់ ប៉ុន្តែនៅសល់តែប្រពន្ធខ្ញុំមួយគត់ដែលនៅចាស់ដដែល ។

**អតីតអនុសេនីយ៍ឯក កែវ មេធ បច្ចុប្បន្នជា Paster**